ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ ជួបប្រតិភូក្រុមហ៊ុន **Kobelco Eco-Solution Co.,LTD**



នៅរសៀលថ្ងៃទី០១ ខែ កញ្ញា ឆ្នាំ២០១៤ ឯកឧត្តម ចម ប្រសិទ្ធ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម បានទទួលជួបប្រតិភូក្រុមហ៊ុន **Kobelco Eco-Solution Co.,LTD** ដឹកនាំដោយលោក **TAKEO YOSHIGAE** អនុប្រធាននាយកដ្ឋាន នៃនាយកដ្ឋានសេវា និងហេដ្ឋារចនាសម្ព័ន្ធទឹក នៃក្រុមហ៊ុន **Kobelco Eco-Solution Co.,LTD** ដើម្បីពិភាក្សាការងារនៅទីស្តីការក្រសួង ។



លោក **TAKEO YOSHIGAE** បានជម្រាបជូនពីមុខសញ្ញាមួយចំនួន ដែលក្រុមហ៊ុនបានធ្វើប្រតិបត្តិការអាជីវកម្មរបស់ខ្លួន រួមមាន ៈផលិតកម្មទឹកស្អាត–រោងចក្រកែច្នៃសម្រាម–អាងប្រព្រឹត្តកម្មទឹកក្រខ្វក់– ជីវៈឧស្ម័ន–ដែក–អាលុយមីញ៉ូម និង គ្រឿងចក្រជាដើម ។ ដោយឡែក នៅកម្ពុជា ក្រុមហ៊ុនបាននាំបច្ចេកវិទ្យាថ្មីមួយ ដើម្បីសុំអាជ្ញាប័ណ្ណធ្វើអាជីវកម្ម

គឺ**អាងប្រព្រឹត្តិកម្មទឹកស្អាត** ដែលជាប្រភេទអាងប្រព្រឹត្តិកម្មមានភាពសាមញ្ញ–ប្រើប្រាស់ទីតាំងតូច–ចំណាយ ពេលសាងសង់ និងតម្លើងក្នុងរយៈពេលខ្លី–ចំណាយដើមទុនតិច និងមិនត្រូវការអ្នកបច្ចេកទេសដើម្បីថែទាំ ព្រោះម៉ាស៊ីននេះ មានការលាងសម្អាតខ្លួនឯងដោយស្វ័យប្រវត្តិ ។ លោក **TAKEO YOSHIGAE** បានបញ្ជាក់ថាៈបច្ចុប្បន្ននៅប្រទេសជប៉ុន ប្រភេទអាងប្រព្រឹត្តិកម្មនេះ ត្រូវបានដាក់ឱ្យប្រើប្រាស់ក្នុងគម្រោងអាជីវកម្មប្រមាណជាងពីរពាន់កន្លែង ហើយនៅកម្ពុជា កសិដ្ឋាន **Soma Group** មានទីតាំងនៅស្រុកបាទី ខេត្តតាកែវ កំពុងដាក់ឱ្យដំណើរការនូវអាងប្រព្រឹត្តិកម្មនេះ ដែលអាច ផលិតបាន ១000 ម៉ែត្រគូបក្នុងមួយថ្ងៃ ។ លោក **YOSHIGAE** បានបន្ថែមថាៈក្រុមហ៊ុននឹងរៀបចំធ្វើសិក្ខាសាលា ដើម្បី ផ្សព្វផ្សាយពីបច្ចេកវិទ្យាថ្មីនេះ នឹងពិនិត្យលទ្ធភាពស្វែងរកដៃគូរក្នុងស្រុក ដើម្បីបង្កើតរោងចក្រផលិតនៅកម្ពុជា ។

ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានសម្តែងការស្វាគមន៍ និងចាត់ទុកមុខសញ្ញាអាជីវកម្មរបស់ក្រុមហ៊ុន សុទ្ធតែមានសារៈសំខាន់សម្រាប់សេដ្ឋកិច្ចកម្ពុជា ។ ទាក់ទង និងអាងប្រព្រឹត្តិកម្មទឹកស្អាតដែលជាប្រព័ន្ធបច្ចេកវិទ្យាថ្មីរបស់ ជប៉ុននេះ ឯកឧត្តមសូមស្វាគមន៍ ពីព្រោះស្របនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាល ក៏ដូចជាក្រសួងឧស្សាហកម្ម និង សិប្បកម្ម ដើម្បីសម្រេចឱ្យបានតាមគោលដៅអភិវឌ្ឍន៍សហសវត្សនៃការទទួលបានទឹកស្អាតប្រើប្រាស់សម្រាប់ប្រជាពលរដ្ឋ នៅទីក្រុង និងទីប្រជុំជន ។ ទោះជាយ៉ាងណា ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានស្នើឱ្យក្រុមហ៊ុនសិក្សាស្រាវជ្រាវ ពីការចំណាយថ្លៃដើម រួមនិងចំណាយប្រតិបត្តិការផ្សេងៗ ដើម្បីរកឱ្យឃើញនូវតម្លៃលក់ទឹកពិតប្រាកដជូនប្រជាពលរដ្ឋ ឱ្យមានលក្ខណៈសមរម្យនិងអាចទទួលយកបាន ជាពិសេស ឱ្យការផ្គត់ផ្គង់ទឹកស្អាតសម្រេចបាននូវគោលការណ៍បីយ៉ាង គឺៈ គុណភាព សុវត្ថិភាព និងនិរន្តភាព ។

ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានស្នើឱ្យក្រុមហ៊ុនបង្កើតការិយាល័យតំណាងរបស់ខ្លួននៅកម្ពុជា និង ស្វាគមន៍ចំពោះការបង្កើតរោងចក្រផលិតនៅកម្ពុជា ព្រមទាំងស្នើឱ្យក្រុមហ៊ុនរៀបចំ ឯកសារពាក់ព័ន្ធ ដើម្បីចូលរួមធ្វើបទ បង្ហាញ ក្នុងសិក្ខាសាលាស្តីពីទឹកស្អាត របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម នាខែ តុលា ខាងមុខនេះ ។ ម៉្យាងទៀត ដើម្បី ស្វែងយល់ជាក់ស្តែង ក្រសួងនឹងរៀបចំប្រតិភូ និងអ្នកបច្ចេកទេស ចុះពិនិត្យដល់កសិដ្ឋាន **Soma Group** ដែលកំពុង ដំណើរការអាងប្រព្រឹត្តិកម្មទឹកស្អាតនេះ ដែលយើងចាត់ទុកថា ជាគម្រោងសាកល្បង ដើម្បីជាមូលដ្ឋានបន្ថែម មុននឹង ចេញអាជ្ញាប័ណ្ណឱ្យក្រុមហ៊ុនធ្វើអាជីវកម្មចែកចាយនូវប្រព័ន្ធអាងប្រព្រឹត្តិកម្មទឹកស្អាតនេះ នៅកម្ពុជា ។

